ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន

# ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា

ភាគ១ • ការិយាល័យចៃកាកម្ពុជា



## គម្រោងអភិវឌ្ឍន៍យន្តការគ្រប់គ្រងការដឹកជញ្ជូនទីក្រុងចម្រុះ

## យន្តការគ្រប់គ្រងការដឹកជញ្ជូនទីក្រុងចម្រុះក្នុងរាជធានីភ្នំពេញ



*កិច្ចប្រជុំ JCC លើកទីពីររបស់គម្រោង*

រាជធានីភ្នំពេញ កំពុងជម្រុញផ្តួចគំនិតផ្តើមយុទ្ធសាស្ត្រមួយដែលទទួលបានការគាំទ្រពី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (ចៃកា) ដើម្បីពង្រឹងសមត្ថភាពសម្រាប់ការរៀបចំផែនការ និងការគ្រប់គ្រងការដឹកជញ្ជូនក្នុងទីក្រុងដ៏ទូលំទូលាយ។ គម្រោងនេះលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនដែលគាំទ្រដល់បរិស្ថានទីក្រុងប្រកបដោយចីរភាព និងឆ្លើយតបទៅនឹងតម្រូវការធ្វើដំណើរដែលកំពុងផ្លាស់ប្តូររបស់ទីក្រុង។

សមាសភាគសំខាន់មួយនៃយុទ្ធសាស្ត្រនេះ គឺការធ្វើបច្ចុប្បន្នភាពផែនការមេដឹកជញ្ជូនទីក្រុងភ្នំពេញ ដែលមានគោលដៅដល់ឆ្នាំ២០៥០។ ផែនការមេដែលបានកែសម្រួលនេះនឹងក្លាយជាក្របខណ្ឌរយៈពេលវែងសម្រាប់ណែនាំការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធការសម្របសម្រួលគោលនយោបាយ និងការកំណត់អទិភាពវិនិយោគ។ តំបន់គោលដៅរួមមាន៖ រាជធានីភ្នំពេញ និងតំបន់ជុំវិញខេត្តកណ្តាល ជាពិសេសទីក្រុងតាខ្មៅ ទីក្រុងអរិយក្សត្រ និងច្រករបៀងចូលអាកាសយានដ្ឋានថ្មី។

គម្រោងនេះត្រូវបានរៀបចំឡើងជុំវិញលទ្ធផលសំខាន់ៗចំនួន៣៖ ទី១ ក្រោមការដឹកនាំគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញ ផែនការមេដឹកជញ្ជូនទីក្រុងភ្នំពេញត្រូវបានធ្វើបច្ចុប្បន្នភាពតាមរយៈដំណើរការនៃការពិគ្រោះយោបល់អន្តរស្ថាប័ន ការពិនិត្យបច្ចេកទេស និងការបង្កើតការយល់ព្រមរួមគ្នា។ ទី២ ក្នុងចំណោមគម្រោងសាកល្បងជាច្រើនគម្រោងសាកល្បងទី២ គឺ Para-transit និង Bus Priority Signal ត្រូវបានជ្រើសរើសដើម្បីបង្កើនសមត្ថភាពសម្រាប់ ការអនុវត្តវិធានការដឹកជញ្ជូនឆ្លងវិស័យ ។ ទី៣ កិច្ចខិតខំប្រឹងប្រែងដំណើរការដើម្បីពង្រឹងរចនាសម្ព័ន្ធអង្គភាពសម្រាប់ការគ្រប់គ្រង និងប្រតិបត្តិការដឹកជញ្ជូនសាធារណៈ រួមទាំងការស្វែងរកក្របខណ្ឌគ្រប់គ្រង និងការកែទម្រង់ស្ថាប័ន។

លើសពីនេះ មន្ត្រីមកពីរដ្ឋបាលរាជធានីភ្នំពេញ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានសាធារណការ និងដឹកជញ្ជូនបានចូលរួមកម្មវិធីបណ្តុះបណ្តាលនៅប្រទេសវៀតណាម (ខែមិថុនា ឆ្នាំ២០២៥) និងប្រទេសជប៉ុន (ខែសីហា ឆ្នាំ២០២៥) ។ កម្មវិធីទាំងនេះបានផ្តល់នូវចំណេះដឹងជាក់ស្តែង អំពីការអភិវឌ្ឍផ្លូវដែកទីក្រុង អភិបាលកិច្ចដឹកជញ្ជូន និងការធ្វើផែន ការរួមបញ្ចូលយេនឌ័រ ដែលត្រូវបានបញ្ចូលក្នុងផែនការសម្មភាព និងការពិភាក្សាបច្ចេកទេស។

ការអនុវត្តគម្រោងនេះត្រូវបានដឹកនាំដោយ រដ្ឋបាលរាជធានីភ្នំពេញ សហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាយកដ្ឋានសាធារណការ និងដឹកជញ្ជូន និងភ្នាក់ងារពាក់ព័ន្ធផ្សេងទៀតតាមរយៈការរីកចម្រើនប្រកបដោយស្មេរភាព និងចូលរួមសហការណ៍ គម្រោងនេះត្រូវបានរំពឹងថានឹងចូលរួមយ៉ាងសំខាន់ ក្នុងការកសាងភាពខ្លាំងរបស់ទីក្រុងភ្នំពេញ និងការផ្លាស់ប្តូរការធ្វើដំណើររយៈពេលវែង៕

គុណ វិច្ឆិកា
ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម
ការិយាល័យចៃកាកម្ពុជា

ទំព័រ ទី១ ២ និង៣

**ព័ត៌មានអំពីគម្រោង**

គម្រោងអភិវឌ្ឍន៍យន្តការគ្រប់គ្រងការដឹកជញ្ជូនទីក្រុងចម្រុះក្នុងរាជធានីភ្នំពេញ



*កិច្ចប្រជុំ JCC លើកទីពីររបស់គម្រោង*

វិស័យដឹកជញ្ជូន និងភស្តុភារ




*ពិធីចុះហត្ថលេខា*

ភាពជាដៃគូ ចៃកាជំរុញការតភ្ជាប់ផ្លូវជនបទនៅកម្ពុជា



*ទីតាំងរបស់គម្រោង*

# វិស័យដឹកជញ្ជូន និងភស្តុភារ

## ការអភិវឌ្ឍន៍ផែនការមេដើម្បីប្រែក្លាយកំពង់ផែក្រុងព្រះសីហនុទៅជា កំពង់ផែ និងមជ្ឈមណ្ឌលឡូជីស្ទីកថ្នាក់តំបន់




ពិធីចុះហត្ថលេខាលើកំណត់ត្រានៃកិច្ចពិភាក្សាស្តីពីគម្រោង

រាជធានីភ្នំពេញ, កាលពីខែកក្កដា ឆ្នាំ២០២៥ រដ្ឋមន្ត្រីនៃក្រសួងសាធារណការ និងដឹកជញ្ជូន បានអញ្ជើញជាគណៈអធិបតីក្នុង ពិធីចុះហត្ថលេខាលើកំណត់ត្រានៃកិច្ចពិភាក្សាស្តីពី គម្រោងអភិវឌ្ឍន៍ផែនការមេ ដើម្បីប្រែក្លាយកំពង់ផែ ក្រុងព្រះសីហនុទៅជាកំពង់ផែ និងមជ្ឈមណ្ឌល ឡូជីស្ទីកថ្នាក់តំបន់ រវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនប្រចាំនៅកម្ពុជា (ចៃកា) ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រសួង ប្រតិភូ ចៃកា និងមន្ត្រីជំនាញពាក់ព័ន្ធ។



ពិធីចុះហត្ថលេខា

រដ្ឋាភិបាលជប៉ុនបានចូលរួមសហប្រតិបត្តិការនៅលើការអភិវឌ្ឍន៍កំពង់ផែសីហនុ រួមទាំងការសាងសងហេដ្ឋារចនាសម្ព័ន្ធ និងការកសាងសមត្ថភាពតាំងពីឆ្នាំ១៩៩៦មកម្ល៉េះ។ នៅក្នុងឆ្នាំ២០២៤ សមត្ថភាពផ្ទុកកុងតឺន័រមានការកើនឡើងរហូតដល់ ១ លាន TEUs លើកដំបូងក្នុងប្រវត្តិសាស្ត្រ។ ដោយសារសេដ្ឋកិច្ចកម្ពុជាបន្តកើនឡើង ចំនួនកុងតឺន័រដែលផ្ទុកនៅក្រុងព្រះសីហនុក៏មានការកើនឡើងផងដែរ។

គោលបំណងនៃគម្រោងនេះ គឺដើម្បីបង្កើតផែនការមេ ប្រែក្លាយកំពង់ផែក្រុងព្រះសីហនុ ទៅជាកំពង់ផែ និង មជ្ឈមណ្ឌលឡូជីស្ទីកថ្នាក់តំបន់ នៅក្នុងឆ្នាំ ២០៥០ តាមរយៈការវិភាគស្ថានភាពបច្ចុប្បន្ន និងការវិភាគពីតម្រូវការចាំបាច់ នាពេលអនាគត។ តាមរយៈគំនិតផ្តួចផ្តើមនេះ ចៃកា និងក្រសួងសាធារណការ និងដឹកជញ្ជូន មានគោលបំណងក្នុងការបង្កើតនូវផែនទីដែលកំណត់ កំពង់ផែក្រុងព្រះសីហនុអោយក្លាយទៅជាមជ្ឈមណ្ឌលឡូជីស្ទីកថ្នាក់តំបន់ ដែលអាចចូលរួមក្នុងការលើកកម្ពស់ប្រព័ន្ធឡូជីស្ទីក និងការកើនឡើង នៃសេដ្ឋកិច្ចកម្ពុជាប្រកបដោយនិរន្តរភាព៕

ប៉ុន សុភានី, ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម
ការិយាល័យចៃកាកម្ពុជា

## JICA IN THE MEDIA

"កម្ពុជា និង JICA នឹងអនុវត្តផែនការមេ លើការគ្រប់គ្រងទីលានទុកដាក់សំរាមកម្រិតតំបន់នៅឆ្នាំក្រោយ"

https://www.postkhmer.com/national/2025-10-8-1055-263466

ភ្នំពេញប៉ុស្តិ៍

០៨ តុលា ២០២៥

"“រោងចក្រប្រព្រឹត្តកម្មទឹកស្អាតតាខ្មៅ និងស្ថានីយបូមទឹកឆៅកោះនរាថ្មី តម្លៃជាង៥១លានដុល្លារត្រូវបានសម្ពោធ”

https://www.postkhmer.com/national/*2025-8-14-1426-262956*

ភ្នំពេញប៉ុស្តិ៍

១៤ សីហា ២០២៥

"ក្រុងព្រះសីហនុនឹងក្លាយជាមជ្ឈមណ្ឌលឡូជីស្ទីកទំនើបតាមរយៈការគាំទ្រពីប្រទេសជប៉ុន"

*ក្រុងព្រះសីហនុនឹងក្លាយជាមជ្ឈមណ្ឌលឡូជីស្ទីកទំនើបតាមរយៈការគាំទ្រពីប្រទេសជប៉ុន -* Khmer Times /

ខ្មែរថែមស៍

០១ សីហា ២០២៥

# ភាពជាដៃគូ ចៃកាជំរុញការតភ្ជាប់ផ្លូវជនបទនៅកម្ពុជា

## ការពង្រឹងសហគមន៍តាមរយៈហេដ្ឋារចនាសម្ព័ន្ធដែលអាចធន់ និងប្រកបដោយចីរភាព




*ទីតាំងរបស់គម្រោង*

រាជរដ្ឋាភិបាលកម្ពុជា ក្នុងភាពជាដៃគូជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (ចៃកា) បានដាក់ចេញនូវគំនិតផ្តួចផ្តើមមួយដើម្បីផ្លាស់ប្តូរការតភ្ជាប់តាមជនបទ និងពង្រឹងផ្នែកសេដ្ឋកិច្ចនៅក្នុងខេត្តជុំវិញផ្លូវជាតិលេខ៥។

គម្រោងកែលម្អការតភ្ជាប់ផ្លូវជនបទ ក្រោមជំនួយចៃកា មានគោលបំណងបង្កើនភាពងាយស្រួលសម្រាប់សហគមន៍ជនបទ ដោយធានាថាប្រជាជនអាចធ្វើដំណើរប្រកបដោយសុវត្ថិភាព និងងាយស្រួលទៅផ្សារ សាលារៀន មណ្ឌលសុខភាព និងសេវាសាធារណៈសំខាន់ៗ ផ្សេងៗទៀតក្នុងមួយឆ្នាំៗ។ លើសពីការសាងសង់ផ្លូវទាំងនេះ ការផ្តួចផ្តើមនេះ បង្ហាញឱ្យឃើញនូវចក្ខុវិស័យរួមសម្រាប់កំណើនរួមបញ្ចូលគ្នានៃការ កាត់បន្ថយភាពក្រីក្រ និងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុនៅទូទាំងប្រទេសកម្ពុជា។

គម្រោងនេះគ្របដណ្តប់លើផ្លូវជនបទ ៣៩ ខ្សែ ដែលមានប្រវែងសរុប ៥១៥គីឡូម៉ែត្រ ក្នុងខេត្តសំខាន់ៗចំនួន៤៖ ខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង និងបន្ទាយមានជ័យ។ ផ្លូវដែលនឹងធ្វើឱ្យប្រសើរឡើងវិញនីមួយៗនេះមានលក្ខណៈពិសេសដោយក្រាលកៅស៊ូពីរជាន់ (DBST) និងផ្លូវបេតុង ដែលមានទទឹងសរុប ៨ម៉ែត្រ ដោយទុកផ្លូវ១ម៉ែត្រសងខាង ដើម្បីបង្កើនសុវត្ថិភាព និងឱ្យចរាចរណ៍ធ្វើដំណើរបានរលូនល្អ។



*ការចុះពិនិត្យលើទីតាំងគម្រោងរវាងចៃកា និង ក្រសួងអភិ.ជនបទ*

ជាមួយនឹងការវិនិយោគសរុបចំនួន ២៣,៦៩២ លានយ៉េនជប៉ុន, គម្រោងនេះបង្ហាញពីមិត្តភាពដ៏រឹងមាំ និងយូរអង្វែងរវាងកម្ពុជា និងជប៉ុនតាមរយៈជំនាញ និងបច្ចេកទេសរបស់ចៃកា និងការប្តេជ្ញាចិត្តរបស់កម្ពុជា ចំពោះការអភិវឌ្ឍប្រកបដោយចីរភាព គម្រោងនេះនឹងជាគម្រូដ៏ល្អនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់សហគមន៍ក្នុងតំបន់។ ផ្លូវជនបទដែលបានកែលម្អនឹងត្រូវបានគេរំពឹងទុកថា នឹងផ្តល់នូវអត្ថប្រយោជន៍ ដែលនឹងផ្លាស់ប្តូររយៈពេលនៃការធ្វើដំណើរលឿនជាងមុន និងថ្លៃដើមដឹកជញ្ជូនទាបជាងមុន ធ្វើឱ្យការធ្វើដំណើរប្រចាំថ្ងៃមានសុវត្ថិភាព និងមានតម្លៃសមរម្យជាងមុន។ សេវាប្រើប្រាស់ការអប់រំ និងការថែទាំសុខភាពកាន់តែប្រសើរឡើង, ផ្តល់ឱ្យកុមារ និងគ្រួសារនូវឱកាសសម្រាប់ការរៀនសូត្រកាន់តែប្រសើរឡើង និងសុខុមាលភាព ក៏ដូចជាពង្រីកឱកាសសេដ្ឋកិច្ចសម្រាប់កសិករ និងសហគ្រិនខ្នាតតូចដែលអាចដឹកជញ្ជូនទំនិញកាន់តែមានប្រសិទ្ធភាពនិងភ្ជាប់ទំនាក់ទំនងជាមួយទីផ្សារកាន់តែទូលំទូលាយ។

អ្វីដែលសំខាន់នោះគម្រោងនេះផ្តោតសំខាន់ទៅលើភាពធន់នឹងអាកាសធាតុ តាមរយៈប្រព័ន្ធបង្ហូរទឹកដែលបានពង្រឹងជើងគ្រឹះផ្លូវដែលបានកែលម្អ និងរចនាសម្ព័ន្ធផ្លូវឱ្យប្រើប្រាស់បានយូរ។

លក្ខណៈពិសេសទាំងនេះ នឹងជួយការពារសហគមន៍ពីទឹកជំនន់ និងផលប៉ះពាល់ផ្សេងទៀតដែលទាក់ទងនឹងអាកាសធាតុ ដោយធានាបាននូវនិរន្តរភាពនៃហេដ្ឋារចនាសម្ព័ន្ធជនបទ សម្រាប់មនុស្សជំនាន់ក្រោយ។ ក្រៅពីការសាងសង់រូបវន្ត គម្រោងកែលម្អការតភ្ជាប់ផ្លូវជនបទតំណាងឱ្យការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍន៍ដែលផ្តោតលើប្រជាជន តាមរយៈការផ្តល់ដល់ប្រជាជនតាមជនបទ ជាមួយនឹងផ្លូវថ្នល់ដែលមានសុវត្ថិភាព និងអាចទុកចិត្តបាន។

ប្រទេសកម្ពុជា នឹងខិតទៅរកការសម្រេចបាននូវគោលដៅជាតិរបស់ខ្លួន ក្នុងការកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់កំណើនសមធម៌ និងការបង្កើនសមាហរណកម្មក្នុងតំបន់៕

គង់ វិសិដ្ឋ
ផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម
ការិយាល័យចៃកាកម្ពុជា

# ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា

# ព័ត៌មានអន្តរជាតិ



## លោកប្រធាន តាណាកា បំពេញទស្សនកិច្ចនៅកម្ពុជា ឡាវ និងថៃ

លោក តាណាកា អាគីហ៊ីកុ ប្រធានចៃកា បានបំពេញទស្សនកិច្ចប្រទេសចំនួន៣គឺ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៥។ លោកប្រធាន តាណាកា បានចូលរួមពិធីខួបលើកទី៦០ នៃកម្មវិធីអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសរបស់ចៃកា និងបានពិនិត្យគម្រោងសហប្រតិបត្តិការរបស់ចៃកា ដោយបានបញ្ជាក់ពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការរហូតមកទល់ពេលនេះ ក៏ដូចជាបញ្ហាប្រឈម និងទស្សនវិស័យសម្រាប់ការអភិវឌ្ឍនាពេលអនាគត។ កម្មវិធីខួបលើកទី៦០ នៃអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសរបស់ចៃកា នីមួយៗរបស់ចៃកាមានដូចជា៖

[កម្ពុជា]



ប្រធាន តាណាកា ផ្តល់សន្ទរកថា

លោកប្រធាន តាណាកា បានចូលរួមពិធីខួបលើកទី៦០ នៃការបញ្ជូនអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការក្រៅប្រទេសរបស់ចៃកា បញ្ជូនមកកាន់ប្រទេសកម្ពុជា។

នៅក្នុងពិធីនោះលោកប្រធាន តាណាកា បានថ្លែងអំណរគុណចំពោះ កិច្ចសហប្រតិបត្តិការរបស់បុគ្គលិក នៃប្រទេសទាំងពីរ ក្រោមពាក្យស្លោក " ភ្ជាប់គំនិតដោយមិនបញ្ឈប់ជំហាន " នឹងបានសម្តែងក្តីសង្ឃឹមថា គម្រោងអ្នកស្ម័គ្រចិត្តសហប្រតិបត្តិការនឹងជួយដោះស្រាយ បញ្ហារបស់ប្រទេសកម្ពុជានាពេលអនាគត។

នៅកម្ពុជា ធ្លាប់មានប្រវត្តិសង្គ្រាមស៊ីវិល សមាជិកចំនួន ៨៤០នាក់ មានសកម្មភាពក្នុងវិស័យអប់រំ ការអភិវឌ្ឍន៍ធនធានមនុស្ស ឧស្សាហកម្ម និងសុខភាព ហើយក៏បានចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជាផងដែរ។

ក្នុងពិធីនេះមានអ្នកចូលរួមប្រមាណ ២០០នាក់ដូចជា ក្រុមអ្នកស្ម័គ្រចិត្តចៃកា មន្ត្រីពាក់ព័ន្ធរបស់ប្រទេសកម្ពុជា និងមានការធ្វើបទបង្ហាញពីក្រុមអ្នកស្ម័គ្រចិត្តពីសកម្មភាពផ្សេងៗរបស់ពួកគេ ក៏ដូចជាការដាក់ពិព័រណ៍តាំងបង្ហាញ។ លោកប្រធាន តាណាកា និងមន្ត្រីរដ្ឋាភិបាលរបស់កម្ពុជា បានរំលឹកឡើងនូវឆ្នាំ នៃការកសាងទំនាក់ទំនងរវាងប្រជាជន និង បានចែករំលែកគំនិតរបស់ពួកគេលើការពង្រឹងទំនាក់ទំនងនៃការជឿទុកចិត្តរវាងជប៉ុន និងកម្ពុជានាពេលអនាគត៕



សកម្មភាពអ្នកស្ម័គ្រចិត្តជប៉ុន

**ផ្នែកទំនាក់ទំនងសាធារណៈ:**

ព័ត៌មានលម្អិតសូមចុចលើតំណរភ្ជាប់ខាងក្រោម៖

*https://www.jica.go.jp/information/press/2025/20251027_11.html*

## ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុនជាមួយយរដ្ឋាភិបាលកម្ពុជា

### ការរួមចំណែកដល់កំណើនសេដ្ឋកិច្ចតាមរយៈការកែលម្អបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងបណ្តាញបញ្ជូនថាមពល

កាលពីថ្ងៃទី១៣ ខែតុលា ទីភ្នាក់សហប្រតិបត្តិការអន្តរជាតិជប៉ុន (ចៃកា) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីជាមួយ រាជរដ្ឋាភិបាលកម្ពុជានៅរាជធានីភ្នំពេញដើម្បីផ្តល់កម្ចីហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការរបស់ ជប៉ុន សម្រាប់គម្រោងចំនួនពីរ។ ការចុះហត្ថលេខានេះត្រូវបានផ្លាស់ប្តូររវាងឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អូន ព័ន្ធមុនីរ័ត្ន នៃរាជរដ្ឋាភិបាលកម្ពុជា និងប្រធានចៃកា លោក តាណាកា អាគីហ៊ីកុ៕



ពិធីចុះហត្ថលេខា

**ផ្នែកទំនាក់ទំនងសាធារណៈ:**

ព័ត៌មានលម្អិតសូមចុចលើតំណរភ្ជាប់ខាងក្រោម៖

*https://www.jica.go.jp/english/information/press/2025/20251014_11.html*

## ទំនាក់ទំនងយើង

**ព្រឹត្តិការណ៍ព័ត៌មានពីកម្ពុជា** គឺជាព្រឹត្តិប័ត្រប្រចាំឆមាសដែលផ្តោតលើទស្សនវិស័យអន្តរជាតិរបស់ចៃកា និងការរួមចំណែករបស់ខ្លួនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក។ ព្រឹត្តិប័ត្រព័ត៌មាននេះរៀបរាប់អំពីការងាររបស់ចៃកាក្នុងប្រទេសកម្ពុជា។

**ការិយាល័យចៃកាប្រចាំនៅកម្ពុជា**

ជាន់ទី ១៦&១៧, អាគារ Keystone, #១៤៦ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរស័ព្ទ៖ +855-(0) 23-238 050

អ៊ីម៉ែល៖ cm_oss_rep@jica.go.jp

**ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន** (ចៃកា) គឺជាទីភ្នាក់ងារជំនួយទ្វេភាគីធំជាងគេបំផុតនៅលើពិភពលោកដែលផ្តល់នូវជំនួយផ្សេងគ្នាជាច្រើនទម្រង់នៅប្រទេសជាង ១៥០ ជុំវិញពិភពលោក។

ស្វែងរកយើងខ្ញុំនៅទីនេះ!

គេហទំព័រ ហ្វេសប៊ុក